អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២១

# សេចក្តីប្រកាសព័ត៌មាន

## អង្គជំនុំជម្រះតុលាការកំពូលបដិសេធ សំណើសុំបញ្ជូនសំណុំរឿង ០០៣ ទៅជំនុំជម្រះ

ថ្ងៃនេះ អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក) បានបដិសេធសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំបញ្ជូនសំណុំរឿង ០០៣ ប្រឆាំងនឹង មាស មុត ទៅជំនុំជម្រះ។

ដោយទទួលបានសំឡេងជាឯកច្ឆ័ន្ទ អង្គជំនុំជម្រះបានសម្រេចថា "បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីការខកខានរបស់អង្គបុរេជំនុំជម្រះ ក្នុងការបញ្ជូនសំណុំរឿង ០០៣ ទៅជំនុំជម្រះ ដូចបានតម្រូវដោយក្របខណ្ឌគតិយុត្តរបស់ អ.វ.ត.ក" អាចទទួលយកបានក្នុងផលប្រយោជន៍យុត្តិធម៌។ ពាក្យស្នើសុំត្រូវបានពិចារណាដោយអង្គជំនុំជម្រះភាគច្រើន ដែលផ្តល់ "ភាពច្បាស់លាស់ និងភាពជាក់លាក់ផ្នែកច្បាប់ និង៖

១) បានបដិសេធការយល់ឃើញដែលថា អង្គបុរេជំនុំជម្រះបានតម្កល់ជាឯកច្ឆ័ន្ទនូវសុពលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះប្រឆាំងនឹង មាស មុត នៅក្នុង សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់ខ្លួន។

២) បានបញ្ជាក់ថា អង្គបុរេជំនុំជម្រះបានបញ្ចប់សំណុំរឿង ០០៣ នៅពេលអង្គជំនុំជម្រះនេះបានចេញសេចក្តីពិចារណារបស់ខ្លួន។

៣) បានបញ្ជាក់បំភ្លឺថា សំណុំរឿង ០០៣ ត្រូវបានបញ្ចប់ ដោយសារគ្មានដីកាបញ្ជូនរឿងទៅជំនុំជម្រះស្ថាពរ និងដែលអាចអនុវត្តបាន។

នៅក្នុងយោបល់ផ្ទុយ លោកស្រីចៅក្រម Maureen Harding Clark បានធ្វើការសន្និដ្ឋាននៅក្នុងការយល់ឃើញរបស់លោកស្រីថា "សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះត្រូវតែបដិសេធចោល ហើយសំណុំរឿង ០០៣ ប្រឆាំងនឹង មាស មុត គប្បីត្រូវបញ្ចប់" ។

សេចក្តីប្រកាសព័ត៌មាននេះ ត្រូវបានផ្សព្វផ្សាយដោយផ្នែកកិច្ចការសាធារណៈ អនុលោមតាមវិធាន ៩(៤) និង ២១(គ) នៃវិធានផ្ទៃក្នុងដើម្បីផ្តល់ព័ត៌មានដល់សាធារណជន។ សេចក្តីសម្រេចនេះអាចរកមើលបាននៅលើគេហទំព័ររបស់ អ.វ.ត.ក៖

https://eccc.gov.kh/sites/default/files/documents/courtdoc/%5Bdate-in-tz%5D/3_1_1_1_KH.PDF

សេចក្តីប្រកាសព័ត៌មាននេះ ត្រូវបានផ្សព្វផ្សាយដោយផ្នែកកិច្ចការសាធារណៈ អនុលោមតាមវិធាន ៩(៤) និង ២១(គ) នៃវិធានផ្ទៃក្នុងដើម្បីផ្តល់ព័ត៌មានដល់សាធារណជន។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក នេត្រ ភក្ត្រា**

ប្រធានផ្នែកកិច្ចការសាធារណៈ និងជាអ្នកនាំពាក្យ

ទូរស័ព្ទ៖ +៨៥៥ (0) ១២ ៤៨៨ ១៥៦

អ៊ីមែល៖ neth.phektra@eccc.gov.kh